សប្តាហ៍ទី 2

អដាំ និងអេវ៉ា

ព្រះជាម្ចាស់បានបង្កើតមនុស្ស

រឿងក្នុងព្រះគម្ពីរ

ព្រះជាម្ចាស់បានបង្កើតអដាំពីដី ហើយដើម្បីឱ្យអដាំមិនឯកោ ព្រះជាម្ចាស់បានបង្កើតអេវ៉ា។ ព្រះជាម្ចាស់បានបង្កើតដើមឈើ ផ្កា និងស្មៅទាំងអស់នៅលើផែនដីនេះ ហើយដាក់អដាំ និងអេវ៉ាឱ្យរស់នៅកន្លែងនោះ។ ព្រះជាម្ចាស់បានបង្កើតមនុស្សមកយ៉ាងអស់ពីព្រះហឫទ័យ។

សមិទ្ធផលសម្រេច



ព្រះជាម្ចាស់បានបង្កើតមនុស្សមកពីដី។

វត្ថុបំណង

- ដឹងថាព្រះជាម្ចាស់បានបង្កើតមនុស្សមក។
- ធ្វើសួនអេដែន ដោយប្រើវត្ថុធម្មជាតិ។
- មានចិត្តអរព្រះគុណ ចំពោះក្តីស្រឡាញ់ និងការបង្កើតមនុស្សយ៉ាងអស់អំពីចិត្តរបស់ទ្រង់។

សម្ភារៈ

- ស្លឹកឈើស្រទាប់ផ្កា ស្មៅ ផ្សេងៗ
- ថ្នាំពណ៌
- រ៉ូឡូលាប
- ក្រដាសរឹង
- កន្ត្រៃ
- ការ៉ែ
- ខ្មៅដៃពណ៌/ហ្វឺត
- ក្រដាសសើម (ឬក្រដាសអនាម័យ)

របៀបធ្វើ

1 ការរើសវត្ថុធម្មជាតិ



ស្វែងរក និងរៀបចំស្លឹកឈើ ស្រទាប់ផ្កា ស្មៅ ច្រើនប្រភេទ។

2 ការលាបថ្នាំពណ៌



លាបថ្នាំពណ៌ឱ្យសព្វនៅលើផ្នែកខាងក្រោយនៃស្លឹក

3 ការផ្តិត



ផ្តិតពីលើក្រដាសដើម្បីបង្កើតទៅជាដើមឈើ ស្មៅ ផ្កា និងមេឃ។

* សូមផ្តិតឆ្លាស់ពណ៌គ្នា។

4 តុបតែងអដាំ និងអេវ៉ា



ជាត់ពណ៌រូបភាពអដាំ និងអេវ៉ា រួចកាត់ បិតលើរូបភាព។

5 ការធ្វើរួច និងការពិភាក្សា



មើលសមិទ្ធផលដែលបានធ្វើរួចបណ្តើរ ពិភាក្សាអំពីព្រះជាម្ចាស់បង្កើតមនុស្សមក។

ការពង្រីកសកម្មភាព

- តុបតែងព្រៃឱ្យកាន់តែស្រស់បំព្រង ដោយស្លឹកឈើដែលមានរូបរាងផ្សេងៗ។
- សរសេរការអរព្រះគុណពីលើរូបដែលបានផ្តិត ធ្វើទៅជាសួនអរព្រះគុណ។
- ទស្សនាសមិទ្ធផលរបស់មិត្តភក្តិទៅវិញទៅមក រួចអរព្រះគុណ។

Tip សម្រាប់គ្រូ

- ប្រសិនបើលាបថ្នាំពណ៌ច្រើនៗពេក វានឹងជ្រាប ដូច្នេះសូមប្រើបរិមាណល្មម។
- សូមផ្តិតសង្កត់ឱ្យខ្លាំង ដើម្បីឱ្យមើលឃើញទ្រនង់របស់ស្លឹកឈើច្បាស់។
- សូមបណ្តុះឱ្យកុមារមានទម្លាប់ចេះឱ្យតម្លៃវត្ថុធម្មជាតិ ចេះរៀបចំឱ្យស្អាតបន្ទាប់ពីប្រើរួច។
- សូមពិភាក្សា «តើព្រះជាម្ចាស់បានបង្កើតមនុស្សមកយ៉ាងផ្ទិតផ្ទង់ប៉ុណ្ណា?»